# ច្បាប់ស្តីពី សវនកម្ម
# នៃព្រះរាជាណាចក្រកម្ពុជា

(បញ្ចូលវិសោធនកម្មចុងក្រោយ ឆ្នាំ២០២១)

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ | Scan QR Code

# ព្រះរាជក្រម

យើង

ជស/រកម/០៣០០/១០

410 7,30

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ និងដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា៤០ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# សវនកម្ម
# នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះជាច្បាប់រៀបចំអង្គការដែលមានគោលបំណងបង្កើតនូវអាជ្ញាធរសវនកម្មជាតិមួយដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ ។ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចចំពោះការអនុវត្តន៍មុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ។ អគ្គសវនករត្រូវបានប្រគល់អំណាចជូនក្នុងការបំពេញសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការនិងកម្មវិធីរបស់បណ្ដាស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាល ។

ច្បាប់នេះក៏បានបង្កើតនូវមុខងារសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាក្រសួង ស្ថាប័ន និងបណ្ដាសហគ្រាសសាធារណៈផងដែរ ។

**មាត្រា ២.-**

បណ្ដាស្ថាប័នគ្រប់គ្រងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ រួមមានបណ្ដាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋនិងស្ថាប័នហិរញ្ញវត្ថុរដ្ឋចំរុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្ដាអង្គការផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្ដល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញនិងសហគ្រាសវិនិយោគឯកជនផង ។

**មាត្រា ៣.-**

ក្នុងច្បាប់នេះ សវនកម្មផ្ទៃក្រៅរាប់បញ្ចូលនូវការអនុវត្តន៍ប្រភេទសវនកម្មដូចតទៅ :

ក-សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ។

ខ-សវនកម្មលើការគ្រប់គ្រងកម្មវិធីគំរោងឥណទានដែលបានទទួលពីមូលនិធិក្រៅប្រទេស ។

គ-សវនកម្មលើប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅលើបណ្ដាស្ថាប័ន ។

ឃ-សវនកម្មលើការវាយតំលៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធិភាពក្នុងការអនុវត្តន៍ ។

ង-សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ សមាគម គណបក្សនយោបាយនិងសវនកម្មលើសហគ្រាសវិនិយោគឯកជន ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះ ។

ច-សវនកម្មតាមសំណើពិសេស ។

**មាត្រា ៤.-**

សវនកម្មផ្ទៃក្រៅ គឺជាការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីកាគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រងដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅនិងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់ការធានាថា :

ក-បណ្តាសកម្មភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍ ។

ខ-បណ្តាសកម្មភាពទាំងនេះត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅ ។

គ-ការត្រួតពិនិត្យនីតិវិធីនិងការអនុវត្តន៍ដោយអនុលោមតាមច្បាប់ បទបញ្ញាកិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធីនិងលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដែលទាក់ទងដល់ចំណូល ចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ប្រភេទសវនកម្ម

**មាត្រា ៥.-**

សវនកម្មលើសេចក្តីថ្លែងការណ៍និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នដែលជាមូលដ្ឋានសំរាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល នៅដំណាច់ឆ្នាំនៃការិយបរិច្ឆេទដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនពេលដាក់ជូនទៅអង្គការនីតិបញ្ញត្តិ ។

សវនកម្មលើភាពត្រឹមត្រូវ ភាពពិតប្រាកដ ការយល់ព្រម ការធ្វើឱ្យមានសុពលភាព និងស្របតាមទិន្នន័យហិរញ្ញវត្ថុ ដូចមានបង្ហាញលើរបាយការណ៍របស់បណ្តាក្រសួង ស្ថាប័ន និងរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល ។

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ អាជ្ញាធរ រួមមានតារាងតុល្យការ របាយការណ៍អំពីប្រាក់ចំណេញ ការខាតបង់ និងការវិភាគគណនីដែលជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។ សវនកម្មនេះ ក៏ត្រូវរាប់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសអាជីវកម្មនៅក្នុងបណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង និងរដ្ឋបាលមូលដ្ឋានផងដែរ ។

**មាត្រា ៦.-**

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ផ្សេងៗទៀតដែលសំណូមពរដោយបណ្តាភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងបណ្តាឥណទាយកនៅក្នុងគំរោងផ្តល់មូលនិធិពីក្រៅប្រទេស ។ សវនកម្មនេះ ត្រូវបញ្ជាក់អំពីភាពសមស្របនឹងភាពត្រឹមត្រូវនៃឯកសារយុត្តិការក្នុងការដកប្រាក់និងការចំណាយលើគំរោងនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុបង្ហាញនូវការសមស្របទៅនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន និងកិច្ចព្រមព្រៀងគំរោង ។ សវនកម្មនឹងបន្តបន្ថែមទៅទៀត លើការវាយតំលៃចំពោះការសំរេចគោលដៅ នៅពេលចប់គំរោងទាំងនោះ ។

**មាត្រា ៧.-**

សវនកម្មលើប្រព័ន្ធត្រួតពិនិត្យនានាដើម្បីរៀបចំនូវមតិលើភាពសមស្របគ្រប់ជ្រុងជ្រោយ ក្នុងការចាត់ចែងប្រព័ន្ធគ្រប់គ្រងនិងការប្រព្រឹត្តទៅ ដែលបានបង្កើតឡើងដោយស្ថាប័នគ្រប់គ្រងលើសកម្មភាពនិងកិច្ចប្រតិបត្តិការទាំងឡាយ ។

**មាត្រា ៨.-**

សវនកម្មលើមុខងារ ឬកិច្ចការកំពុងអនុវត្តរវាងស្ថាប័នគ្រប់គ្រង និងស្ថាប័នគ្រប់គ្រងដើម្បីធានាសកម្មភាពកិច្ចប្រតិបត្តិការដែលទាក់ទងដល់មុខងារនៅក្នុងបណ្តាស្ថាប័នគ្រប់គ្រងឱ្យអនុវត្តគោរពតាមច្បាប់ បទបញ្ញា និងគោលការណ៍ទាំងឡាយកំពុងអនុវត្ត ។ សវនកម្មនេះ រាប់បញ្ចូលទាំងលទ្ធកម្មសាធារណៈ បៀវត្សបុគ្គលិក កិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងបេសកកម្ម ។

**មាត្រា ៩.-**

សវនកម្មដើម្បីវាយតំលៃអំពីការសន្សំសំចៃ ការផ្តល់ឱ្យនូវផលល្អ ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលទ្ធផលនៃកម្មវិធីរបស់រាជរដ្ឋាភិបាល ។ សវនកម្មនេះ រាប់បញ្ចូលទាំងការពិនិត្យពិចារណាឡើងវិញនៃកិច្ចប្រតិបត្តិការរបស់បណ្តាស្ថាប័នសាធារណៈ ទោះជាស្ថាប័នហិរញ្ញវត្ថុ ឬមិនមែនស្ថាប័នហិរញ្ញវត្ថុក៏ដោយ ។

**មាត្រា ១០.-**

សវនកម្មលើការអនុវត្តន៍ស្របតាមបទប្បញ្ញត្តិជាធរមាន ក្នុងកិច្ចប្រតិបត្តិការរបស់អង្គការដែលមិនរកប្រាក់ចំណេញ សមាគមនិងគណបក្សនយោបាយដែលបានទទួលជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលក្នុងទ្រង់ទ្រាយលើកលែងពន្ធគយ ពន្ធលើប្រាក់បៀវត្ស និងពន្ធអាករឯទៀត ព្រមទាំងបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដែលពុំមានការអនុញ្ញាតដោយច្បាប់ ។ គោលដៅនៃសវនកម្មនេះ គឺដើម្បីកុំឱ្យរាជរដ្ឋាភិបាលត្រូវបានបាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីការលើកលែងពន្ធ និងដើម្បីធានាថាស្ថាប័នគ្រប់គ្រងបានដំណើរការទៅតាមក្របខ័ណ្ឌនៃគោលបំណងរបស់ខ្លួន ។

**មាត្រា ១១.-**

សវកម្មលើការអនុវត្តន៍ស្របតាមបទប្បញ្ញត្តិជាធរមានរបស់សហគ្រាសវិនិយោគឯកជនដែលបានទទួលការលើកលែងពន្ធ និងសម្បទានពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សវនកម្មទាំងនេះសង្កត់ធ្ងន់ទៅលើការអនុវត្តន៍ទៅតាមកិច្ចព្រមព្រៀង និងបណ្តាលក្ខខណ្ឌនៃការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

**មាត្រា ១២.-**

សវនកម្មតាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុនិងធនាគារនៃរដ្ឋសភា ឬរដ្ឋសភា ឬព្រឹទ្ធសភា ឬក្រសួង ឬស្ថាប័ននានា ឬអាជ្ញាធរសំរាប់ធ្វើការត្រួតពិនិត្យពិសេសឡើងវិញលើវិស័យមួយផ្នែក ឬទាំងអស់នៃកិច្ចប្រតិបត្តិការរបស់ម្ចាស់សំណើ ។ ការអនុវត្តន៍នៃសវនកម្មដែលមានចែងក្នុងមាត្រានេះ គឺស្ថិតនៅលើឆន្ទានុសិទ្ធិរបស់អគ្គសវនករ ។

**មាត្រា ១៣.-**

សវនកម្មដែលមានចែងពីមាត្រា ៥ ដល់មាត្រា ១២ ត្រូវធ្វើដោយអាជ្ញាធរសវនកម្មជាតិ ។

## ជំពូកទី ៣

## អាជ្ញាធរសវនកម្មជាតិ

**មាត្រា ១៤.-**

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាពត៌មាន ។ អាជ្ញាធរសវនកម្មជាតិដឹកនាំដោយអគ្គសវនករមួយរូបនិងមានអគ្គសវនករង២ (ពីរ)រូប ។

**មាត្រា ១៥.-**

ក្នុងការបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីអនុវត្តច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានសិទ្ធិអំណាចចេញសេចក្ដីសំរេច បទបញ្ជា សារាចរ និងការណែនាំផ្សេងៗទៀត ។

**មាត្រា ១៦.-**

មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិមានលក្ខន្តិកៈដោយឡែក ។

**មាត្រា ១៧.-**

អាជ្ញាធរសវនកម្មជាតិមានថវិកាដោយឡែករបស់ខ្លួនផ្ដល់ដោយថវិកាជាតិ ។ ការគ្រប់គ្រងចំណូលនិងចំណាយនៃអាជ្ញាធរសវនកម្មជាតិ ត្រូវស្ថិតនៅក្រោមច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## ការតែងតាំងអគ្គសវនករ និងអគ្គសវនកររង

**មាត្រា ១៨.-**

អគ្គសវនករ និងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល និងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសំលេងគាំទ្រ ២/៣ (ពីរភាគបី) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

អគ្គសវនករនិងអគ្គសវនកររង នឹងត្រូវបានទទួលការតែងតាំងសំរាប់អាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយអាចទទួលការតែងតាំងតែមួយដងទៀតប៉ុណ្ណោះ នៅពេលចប់អាណត្តិទី ១ របស់ខ្លួន ។

ក្នុងករណីដែលអគ្គសវនករ ឬអគ្គសវនកររងទទួលអនិច្ចកម្ម ឬលាលែង ឬបាត់បង់សមត្ថភាពពលកម្ម ឬមានកំហុសជាទម្ងន់នោះ ត្រូវជ្រើសតាំងអគ្គសវនករ ឬអគ្គសវនកររងថ្មីជំនួសតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ ។

អគ្គសវនករមានឋានៈនិងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។

**មាត្រា ១៩.-**

បេក្ខជនដែលត្រូវជ្រើសរើសមកតែងតាំងជាអគ្គសវនករ អគ្គសវនកររងត្រូវជាឥស្សរជន :

- មានសញ្ជាតិខ្មែរពីកំណើត
- មានសញ្ញាប័ត្រពីថ្នាក់ឧត្តមសិក្សាឡើងទៅ ឬសញ្ញាប័ត្រសមមូលផ្នែកគណនេយ្យ ឬសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ ឬច្បាប់ ឬពាណិជ្ជកម្មដែលមានបញ្ជាក់ទទួលស្គាល់ច្បាស់លាស់
- មានបទពិសោធន៍ខាងវិជ្ជាជីវៈ ឬការងារយ៉ាងតិច ១០ (ដប់) ឆ្នាំឡើងទៅ
- មិនមានតួនាទីក្នុងអង្គការដឹកនាំនៃគណបក្សនយោបាយណាមួយ ។

**មាត្រា ២០.-**

អគ្គសវនករមានតួនាទីជាអ្នកដឹកនាំនៃអាជ្ញាធរសវនកម្មជាតិ ដែលត្រូវទទួលខុសត្រូវលើការអនុវត្តន៍គោលនយោបាយ គោលដៅ គោលបំណងរបស់អាជ្ញាធរសវនកម្មជាតិ និងមានសិទ្ធិដើម្បីធ្វើសកម្មភាពលើរាល់កិច្ចការទាំងអស់ដែលមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ២១.-**

អគ្គសវនករជាអ្នកតែងតាំង ផ្លាស់ប្តូរ ធ្វើកម្មវិធាននិងកំណត់បៀវត្ស អត្ថប្រយោជន៍ ប្រាក់កំរៃ ប្រាក់រង្វាន់ ដល់មន្ត្រីរាជការនិងបុគ្គលិករបស់អាជ្ញាធរសវនកម្មជាតិ ។

# ជំពូកទី ៥
## របាយការណ៍នៃសវនកម្ម

**មាត្រា ២២.-**

រាជរដ្ឋាភិបាលត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ ទៅរដ្ឋសភា ព្រឹទ្ធសភាដើម្បីពិនិត្យនិងអនុម័ត ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏ត្រូវបញ្ជូនឯកសារនេះទៅអាជ្ញាធរសវនកម្មជាតិដើម្បីធ្វើសវនកម្មដែរ ។ អាជ្ញាធរសវនកម្មជាតិត្រូវធ្វើរបាយការណ៍សវនកម្មបញ្ជាក់លើឯកសារនេះទៅរដ្ឋសភា ព្រឹទ្ធសភា ។

**មាត្រា ២៣.-**

បើក្នុងរយៈពេល ៤ (បួន) ខែបន្ទាប់ពីដំណាច់ឆ្នាំនៃការិយបរិច្ឆេទ រាជរដ្ឋាភិបាលមិនបានផ្តល់ឯកសារស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំមកអាជ្ញាធរសវនកម្មជាតិទេ អគ្គសវនករត្រូវធ្វើរបាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភាស្តីពីការខកខាននេះ ។

**មាត្រា ២៤.-**

អគ្គសវនករត្រូវរាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ក្នុងករណីដែលអង្គភាពណាមួយមានភាពមិនប្រក្រតីនៅក្នុងកិច្ចបញ្ជីកាគណនេយ្យ ការគ្រប់គ្រងរូបិយវត្ថុនិងទ្រព្យសកម្ម ។

**មាត្រា ២៥.-**

អគ្គសវនករត្រូវធ្វើរបាយការណ៍និងធ្វើកំណត់សំគាល់ជាទូទៅលើបណ្តាបញ្ហាដែលទាក់ទងដល់កិច្ចបញ្ជីកាគណនេយ្យ រូបិយវត្ថុ ទ្រព្យសកម្ម និងបំណុលអកម្មផ្សេងៗទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។

**មាត្រា ២៦.-**

ទោះបីជាមានបទប្បញ្ញត្តិណាផ្សេងទៀតក៏ដោយដែលស្តីពីសវនកម្ម អគ្គសវនករធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យរបស់អាជ្ញាធរ ឬស្ថាប័ននោះ ត្រូវផ្តល់លិខិតបញ្ជាក់និងរបាយការណ៍ផ្សេងទៀត ដែលយល់ថាជាការចាំបាច់ចំពោះកិច្ចបញ្ជីកាគណនេយ្យនោះ ទៅឱ្យអ្នកដឹកនាំអាជ្ញាធរ ឬស្ថាប័ននោះ និងទៅរដ្ឋសភា ព្រឹទ្ធសភានិងក្រសួងពាក់ព័ន្ធ ។

**មាត្រា ២៧.-**

អគ្គសវនករត្រូវរាយការណ៍ជូនរដ្ឋសភា ព្រឹទ្ធសភាជាប្រចាំនូវបញ្ហាទាំងឡាយណាដែលកើតចេញពីការបំពេញភារកិច្ច ឬប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ២៨.-**

ក្រោយពីមានការរៀបចំរបាយការណ៍ស្តីពីសវនកម្មនៃកិច្ចប្រតិបត្តិការរបស់អង្គភាពណាមួយ អគ្គសវនករត្រូវជូនច្បាប់ចំលងរបាយការណ៍នោះទៅប្រធានស្ថាប័នគ្រប់គ្រង ។ ប្រសិនបើប្រធានស្ថាប័នគ្រប់គ្រងនោះបានជូនយោបល់ជាលាយលក្ខអក្សរទៅអគ្គសវនករ ក្នុងអំឡុងពេល ២៨ (ម្ភៃប្រាំបី)ថ្ងៃ អគ្គសវនករត្រូវពិចារណាលើយោបល់ទាំងនោះ មុនពេលរៀបចំរបាយការណ៍ចុងក្រោយ ។ ផ្ទុយទៅវិញ បើប្រធានស្ថាប័ននោះមិនឆ្លើយតបតាមកាលកំណត់ខាងលើ របាយការណ៍នោះត្រូវចាត់ទុកជាបានការ ។

**មាត្រា ២៩.-**

របាយការណ៍ដែលធ្វើដោយអគ្គសវនករ ត្រូវបានចាត់ទុកជាឯកសារសាធារណៈ។

## ជំពូកទី ៦
## សិទ្ធិអំណាចលើការប្រមូលផ្តុំព័ត៌មាន

**មាត្រា ៣០.-**

អគ្គសវនករអាចតំរូវតាមរយៈលិខិតទៅប្រធាន ឬតំណាងស្ថាប័នពាក់ព័ន្ធអោយៈ

ក-ផ្តល់ដល់អគ្គសវនករ ឬមន្ត្រីមានការអនុញ្ញាតនូវព័ត៌មានអ្វីដែលត្រូវការ ។ មន្ត្រីមានការអនុញ្ញាតគឺមន្ត្រីដែលអគ្គសវនករបានអនុញ្ញាតជាលាយលក្ខអក្សរអោយអនុវត្តមុខនាទីនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

ខ-ចូលរួមនិងប្រគល់ភស្តុតាងចំពោះមុខអគ្គសវនករ ឬមន្ត្រីមានការអនុញ្ញាត។

គ-ប្រគល់រាល់ឯកសារនានា ក្រោមការគ្រប់គ្រងរបស់ប្រធាន ឬតំណាងស្ថាប័នពាក់ព័ន្ធនេះទៅអគ្គសវនករ ឬមន្ត្រីមានការអនុញ្ញាត ។

**មាត្រា ៣១.-**

អគ្គសវនករអាចតំរូវអោយ :

ក-ផ្តល់ពត៌មានដោយផ្ទាល់មាត់ ឬជាលាយលក្ខអក្សរហើយបញ្ជាក់ថាត្រឹមត្រូវនៅចំពោះមុខច្បាប់ ។

ខ-អគ្គសវនករមានសិទ្ធិបញ្ជាក់រកការពិតនូវពត៌មាន និងរកភស្តុតាងជាក់លាក់ដែលបានផ្តល់ទាំងនោះ ។

**មាត្រា ៣២.-**

អគ្គសវនករឬមន្ត្រីមានការអនុញ្ញាត :

ក-អាចចូលនិងស្ថិតនៅអង្គភាពដែលត្រូវធ្វើសវនកម្មគ្រប់ពេលម៉ោងធ្វើការ ។

ខ-មានសិទ្ធិពេញលេញនិងដែកឆេរដោយសេរីរាល់ឯកសារ របាយការណ៍ ឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រសួងស្ថាប័នទាំងនោះ ។

គ-អាចត្រួតពិនិត្យថតចំលង ឬដកស្រង់ឯកសារពីរបាយការណ៍ណាមួយក៏បាន ។

**មាត្រា ៣៣.-**

មន្ត្រីដែលមានការអនុញ្ញាត មុនពេលចូល និងស្ថិតនៅអង្គភាពដែលត្រូវធ្វើសវនកម្ម ត្រូវបង្ហាញលិខិតអនុញ្ញាតដែលចុះហត្ថលេខាដោយអគ្គសវនករ ។ ម្ចាស់ស្ថាប័នឬអង្គភាពត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីមានការអនុញ្ញាត ក្នុងការធ្វើសវនកម្មនៅពេលបានឃើញលិខិតអនុញ្ញាតនេះ ។

**មាត្រា ៣៤.-**

ត្រូវហាមឃាត់ចំពោះអ្នកផ្តល់ពត៌មាននូវការក្លែងបន្លំរបាយការណ៍ ទោះជារបាយការណ៍ផ្ទាល់មាត់ ឬជាលាយលក្ខអក្សរ ។

## ជំពូកទី ៧
## ការសម្ងាត់នៃពត៌មាន

**មាត្រា ៣៥.-**

ប្រសិនបើមន្ត្រីមានការអនុញ្ញាតណាមួយបានទទួលពត៌មានដោយផ្ទាល់ ឬដោយប្រយោលក្នុងដំណើរនៃការអនុវត្តន៍មុខនាទីមួយនៅក្នុងច្បាប់នេះ មន្ត្រីនោះមិនត្រូវលាតត្រដាង បកស្រាយ ឬផ្តល់ពត៌មានទៅមជ្ឈដ្ឋានខាងក្រៅឡើយ លើកលែងតែការអនុវត្តន៍មុខនាទីភារកិច្ចផ្ទៃក្នុងរបស់អាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ៣៦.-**

ការហាមឃាត់នៅក្នុងមាត្រា ៣៥ នៃច្បាប់នេះ ពុំមានប៉ះពាល់ទៅលើការលាតត្រដាង ការបកស្រាយ ការផ្តល់ពត៌មាននៅក្នុងរបាយការណ៍នូវសេចក្តីសន្និដ្ឋាន ការកត់សំគាល់ ឬការសង្កេតរបស់អគ្គសវនករឡើយ ។

**មាត្រា ៣៧.-**

អគ្គសវនករមិនត្រូវបញ្ចូលពត៌មានពិស្តារនៅក្នុងរបាយការណ៍ដែលត្រូវផ្សព្វផ្សាយជាសាធារណៈទេ ប្រសិនបើ :

ក-អគ្គសវនករយល់ថា ការលាតត្រដាងពត៌មានគឺជាការផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ លើហេតុផលណាមួយដែលមានបញ្ជាក់នៅក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

ខ-រាជរដ្ឋាភិបាលបានចេញលិខិតបញ្ជាក់មួយទៅអគ្គសវនករថា ការលាតត្រដាងពត៌មាននេះគឺជាការផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ តាមហេតុផលណាមួយដែលមានបញ្ជាក់នៅក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ក្នុងគោលបំណងនៃមាត្រា ៣៧ នៃច្បាប់នេះ ហេតុផលខាងក្រោមនេះត្រូវបានចាត់ទុកថាជាពត៌មានដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ÷

ក-ប៉ះពាល់ដល់សន្តិសុខ ការការពារជាតិ និងបូរណភាពទឹកដី ឬទំនាក់ទំនងអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

ខ-ប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់បណ្តាអង្គភាព ឬបុគ្គល ។

មាត្រា ៣៩.-

យោងតាមមាត្រា ៣៧ នៃច្បាប់នេះ អគ្គសវនករសំរេច :

ក-មិនរៀបចំរបាយការណ៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ ។

ខ-លុបចោលពត៌មានពិស្តារក្នុងរបាយការណ៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ ។

ប៉ុន្តែចំពោះរបាយការណ៍បង្ហាញជូនរដ្ឋសភា ព្រឹទ្ធសភា ឬក្រសួងពាក់ព័ន្ធ អគ្គសវនករ ត្រូវរៀបចំបញ្ចូលពត៌មានពិស្តារដែលបានហាមឃាត់ដូចមានចែងនៅក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

## ជំពូកទី ៨
## សវនកម្មលើអាជ្ញាធរសវនកម្មជាតិ

មាត្រា ៤០.-

ក្នុងករណីចាំបាច់ តាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុនិងធនាគារនៃរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនាមនៃរដ្ឋសភាមានសិទ្ធិជ្រើសរើសសវនករពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ ។

## ជំពូកទី ៩
## ការបង្កើតសវនកម្មផ្ទៃក្នុង

មាត្រា ៤១.-

សវនកម្មផ្ទៃក្នុងត្រូវបង្កើតឡើងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះ ទៅអាជ្ញាធរសវនកម្មជាតិ ។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤២.-**

សវនកម្មផ្ទៃក្នុងមានភារកិច្ចធ្វើការពិនិត្យវាយតំលៃដោយឯករាជ្យ លើប្រសិទ្ធិភាពក្នុងការអនុវត្តន៍នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់បណ្តាស្ថាប័ន ក្រសួងនិងសហគ្រាសសាធារណៈ ។

**មាត្រា ៤៣.-**

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងគឺជាដំណើរការរបស់រាជរដ្ឋាភិបាល ដែលធ្វើឡើងដោយថ្នាក់ដឹកនាំស្ថាប័ន ក្រសួងនិងសហគ្រាសសាធារណៈ ដើម្បីផ្តល់នូវការធានាភាពសមស្របលើសមិទ្ធិកម្មនៃកម្មវត្ថុតាមបណ្តាផ្នែកខាងក្រោម :

ក-ប្រសិទ្ធិភាពនៃកិច្ចប្រតិបត្តិការ ។

ខ-ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ ។

គ-ភាពសមស្របតាមបណ្តាច្បាប់ បទបញ្ញា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្ត ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ៤៤.-**

ដោយពុំទាន់គិតដល់ការផ្តន្ទាទោសផ្សេងទៀត ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣១ ឬមាត្រា ៣៣ នៃច្បាប់នេះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល ឬដាក់ពន្ធនាគារពី ១ (មួយ) ខែដល់ ៣(បី)ខែ ឬពិន័យជាប្រាក់ផង និងដាក់ពន្ធនាគារថែមទៀតផង ។

**មាត្រា ៤៥.-**

ដោយពុំទាន់គិតដល់ការផ្តន្ទាទោសផ្សេងទៀត ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៤ នៃច្បាប់នេះ នឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ៥.០០០.០០០ (ប្រាំលាន) រៀលឡើងទៅ ឬដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ ឬពិន័យជាប្រាក់ផងនិងដាក់ពន្ធនាគារថែមទៀតផង ។

# ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៤៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤៧.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០០០

ក្នុងព្រះបរមនាម និង តាមព្រះរាជព្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ : ៤០ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៤ ខែមិនា ឆ្នាំ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

# ព្រះរាជក្រម

នស/រកម/១០២១/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល
លេខ ២១២៩
ថ្ងៃទី ២៧/១០ ឆ្នាំ ២០២១ ម៉ោង ៩:៣០
បញ្ជូនទៅ ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ព្រមទាំងមានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ២១៤/០០១/២០២១ ក.ប.ធ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

# វិសោធនកម្មមាត្រា១៨ថ្មី
# នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨
# នៃច្បាប់ស្តីពីសវនកម្ម
# នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រាមួយ .-**

មាត្រា១៨ថ្មីនៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១៨ .- ថ្មី(ពីរ)**

អគ្គសវនករនិងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាលនិងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

អគ្គសវនករនិងអគ្គសវនកររង នឹងត្រូវបានទទួលការតែងតាំងសម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ ហើយអាចទទួលការតែងតាំងជាថ្មី។

ក្នុងករណីដែលអគ្គសវនករឬអគ្គសវនកររងទទួលអនិច្ចកម្មឬលាលែងឬបាត់បង់សមត្ថភាពពលកម្មឬមានកំហុសជាទម្ងន់នោះ ត្រូវជ្រើសតាំងអគ្គសវនករឬអគ្គសវនកររងថ្មីជំនួសតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ។

អគ្គសវនករមានឋានៈនិងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ១០កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២១

នស/រកម.១០២១.០១៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**